ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
លេខ : ៤៤ ឃ.ខ.សណន

# សេចក្តីណែនាំ
# ស្តីពី
# វិធានការបង្កើនប្រសិទ្ធភាពនិងពង្រឹងគុណភាពសេវាទូរគមនាគមន៍

ក្នុងគោលបំណងលើកកម្ពស់ផលប្រយោជន៍សាធារណៈ និងការធ្វើអាជីវកម្មប្រកបដោយសុចរិតភាពនិងការទទួលខុសត្រូវចំពោះសង្គម តាមរយៈការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាទូរគមនាគមន៍និងពង្រឹងគុណភាពសេវាទូរសព្ទចល័តក៏ដូចជាសេវាអ៊ីនធឺណិត ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (ក.ប.ទ) សូមជម្រាបជូនប្រតិបត្តិករទូរគមនាគមន៍និងសាធារណជនទាំងអស់ មេត្តាជ្រាបថា ក.ប.ទ បាននិងកំពុងខិតខំបញ្ចប់ការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការពង្រឹងគុណភាពសេវាទូរគមនាគមន៍ ការពិន័យអន្តរការណ៍ និងទណ្ឌកម្មផ្សេងៗចំពោះប្រតិបត្តិករទូរគមនាគមន៍ដែលមិនគោរពច្បាប់ស្តីពីទូរគមនាគមន៍ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគោលការណ៍នៃការផ្តល់សេវាប្រកបដោយគុណភាព។ ទន្ទឹមនឹងនេះ ក.ប.ទ បាននិងកំពុងវាស់ស្ទង់គុណភាពសេវាទូរគមនាគមន៍នៅតាមតំបន់នីមួយៗ ដើម្បីកំណត់ចំណុចខ្សោយ ឬបញ្ហានានាពាក់ព័ន្ធនឹងគុណភាពសេវា និងដាក់ចេញនូវវិធានការដាក់ស្តែង។ បន្ថែមលើនេះ ក.ប.ទ នឹងតម្រូវឱ្យប្រតិបត្តិករទូរគមនាគមន៍វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចាំបាច់។ ក.ប.ទ នឹងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីសម្របសម្រួលឱ្យមានប្រសិទ្ធភាពខ្ពស់។ ការងារទាំងអស់ខាងលើនេះគឺជាសកម្មភាពអាទិភាពបំផុតនៃកម្មវិធីកំណែទម្រង់វិស័យទូរគមនាគមន៍របស់ក្រសួង។

ដើម្បីសម្រេចបាននូវផែនការសកម្មភាពនិងកម្មវិធីកំណែទម្រង់លើវិស័យទូរគមនាគមន៍នេះ ក.ប.ទ តម្រូវឱ្យមានការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ដូចជា៖

**១. ប្រតិបត្តិករទូរគមនាគមន៍៖**

- ត្រូវគោរពច្បាប់ស្តីពីទូរគមនាគមន៍និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធឱ្យបានខ្ជាប់ខ្ជួន
- ត្រូវសិក្សានិងធ្វើបច្ចុប្បន្នភាពផែនការសាងសង់ស្ថានីយអង់តែន ឆ្លើយតបនឹងការប្រើប្រាស់ ចំនួនអ្នកប្រើប្រាស់ និងទីតាំងភូមិសាស្ត្រ ដោយត្រូវផ្តល់ផែនការនេះមកនិយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក)
- ត្រូវស្នើសុំមក ន.ទ.ក មុនសាងសង់ស្ថានីយអង់តែន និងបណ្តាញទូរគមនាគមន៍ ស្របតាមមាត្រា១៤ និង ១៧ នៃច្បាប់ស្តីពីទូរគមនាគមន៍
- ត្រូវសុំការអនុញ្ញាតនាំចូល-នាំចេញ ផ្គត់ផ្គង់និងចែកចាយ និងវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ នៃគ្រឿងបរិក្ខារទូរគមនាគមន៍ មក ន.ទ.ក ស្របតាមមាត្រា១៤ ១៥ និង ១៦ នៃច្បាប់ស្តីពីទូរគមនាគមន៍
- ត្រូវមានថាមពលអគ្គិសនីគ្រប់គ្រាន់ និងមានប្រភពអគ្គិសនីត្រៀមបម្រុងតាមស្ថានីយអង់តែននីមួយៗ
- ជៀសវាងការប្រើប្រាស់និងការដំឡើងឧបករណ៍ទូរគមនាគមន៍ ដូចជា ឧបករណ៍ក្លូន ឧបករណ៍ចាស់ ឬការដំឡើងផ្ទុយពីស្តង់ដារបច្ចេកទេស ជាដើម


អាសយដ្ឋាន : អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
គេហទំព័រ : www.mptc.gov.kh
ទូរសព្ទ : (៨៥៥) ២៣ ៧២៤ ៨១០
ទូរសារ : (៨៥៥) ២៣ ៧២៤ ០១៩
អ៊ីមែល : info@mptc.gov.kh

- ត្រូវរៀបចំ និងកែសម្រួលនិម្មាបនកម្មបណ្ដាញ (Network Architecture) ដោយមានសេណារីយ៉ូត្រៀមបម្រុងធានាស្ថិរភាពខ្ពស់ក្នុងការផ្ដល់សេវា
- ត្រូវពង្រឹងយន្តការថែទាំ តាមដាន ត្រួតពិនិត្យលើប្រតិបត្តិការរបស់ស្ថានីយផ្សាយសេវា (BTS/NodeB/eNodeB) និងបណ្ដាញតភ្ជាប់ជាប្រចាំ ព្រមទាំងត្រូវពង្រីកសមត្ថភាពនៃស្ថានីយផ្សាយសេវា និងបណ្ដាញតភ្ជាប់ ជៀសវាងការកាត់ផ្ដាច់ ឬការកកស្ទះដោយថាហេតុ
- ត្រូវជួសជុលឱ្យបានទាន់ពេលវេលាលើការប៉ះពាល់ដល់ខ្សែកាប្លិ៍អុបទិកក្រោមដី ដែលបណ្ដាលមកពីការស្ថាបនា ឬការពង្រីកផ្លូវបន្ថែម
- ត្រូវផ្ដត់ផ្ដង់សេវាអ៊ីនធឺណិតស្របតាមស្តង់ដារបច្ចេកទេស (Sharing Factor) ទៅឱ្យអ្នកប្រើប្រាស់ដោយមិនត្រូវលើសចំណុះសមត្ថភាព (Capacity) ដែលខ្លួនមាន
- ត្រូវបញ្ជាក់ទំហំទិន្នន័យនិងតម្លៃឱ្យបានច្បាស់លាស់ក្នុងពេលផ្សាយពាណិជ្ជកម្ម ឈរលើគោលការណ៍សុចរិតភាពនិងស្មោះត្រង់
- មិនត្រូវផ្ដត់ផ្ដង់សេវាអ៊ីនធឺណិតដែលមានល្បឿនទាបជាងកញ្ចប់សេវាអ៊ីនធឺណិតដែលខ្លួនបានផ្សព្វផ្សាយពាណិជ្ជកម្មនិងបានលក់ទៅឱ្យអ្នកប្រើប្រាស់ ។

## ២. ម្ចាស់បុរីនិងអគារខ្ពស់៖

- មិនត្រូវចុះកិច្ចសន្យាផ្ដល់សិទ្ធិផ្ដាច់មុខដល់ប្រតិបត្តិករ ដើម្បីផ្ដល់សេវាទូរសព្ទនិងសេវាអ៊ីនធឺណិតក្នុងទីតាំងបុរី ឬអគារខ្ពស់ ផ្ទុយពីគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ ស្មើភាព និងស្របច្បាប់ឡើយ
- ត្រូវរៀបចំទីតាំងបម្រុងទុកសម្រាប់សាងសង់ស្ថានីយអង់តែនក្នុងបុរី ឬរៀបចំបង្គោលភ្លើងដែលមានលទ្ធភាពបំពាក់ឧបករណ៍ផ្ដល់សេវាទូរគមនាគមន៍
- ត្រូវសហការជាមួយប្រតិបត្តិករ ដើម្បីបំពាក់ប្រព័ន្ធផ្ដល់សេវាក្នុងអគារ (In-building Solutions)
- ត្រូវចាត់ទុកថា សេវាទូរគមនាគមន៍គឺជាសេវាចាំបាច់ ដូចគ្នានឹងសេវាអគ្គិសនីនិងទឹកដែរ។

## ៣. ប្រជាពលរដ្ឋ៖

- អង្គការសុខភាពពិភពលោក (WHO) បានបញ្ជាក់យ៉ាងច្បាស់ថា រលកហ្វ្រេកង់វិទ្យុមិនបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពរបស់អ្នករស់នៅជុំវិញទេ។ ការសាយភាយរលកហ្វ្រេកង់វិទ្យុពីស្ថានីយអង់តែន មិនមែនជាការសាយភាយរលកវិទ្យុសកម្មទេ។ គ្រប់ប្រទេសលើពិភពលោកក៏បានសាងសង់និងប្រើប្រាស់ស្ថានីយអង់តែន ដើម្បីផ្ដល់សេវាទូរគមនាគមន៍ ដូចប្រទេសកម្ពុជាដែរ។ ប្រសិនបើមិនមានស្ថានីយអង់តែន ក៏មិនអាចមានសេវាទូរសព្ទចល័តដែរ ហើយប្រសិនបើមានផលប៉ះពាល់ដល់សុខភាព ប្រទេសទាំងអស់នឹងពុំមានស្ថានីយអង់តែនដែរ
- មិនត្រូវរារាំងការសាងសង់ស្ថានីយអង់តែនលើទីតាំងរបស់កម្មសិទ្ធិករដទៃ ដោយយកហេតុផលសុខភាពនោះទេ។ ការរារាំងនេះជាអំពើល្មើសច្បាប់ ដែលមានក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- គួរប្រើប្រាស់ទូរសព្ទឆ្លាត (Smart phone) ដែលមានគុណភាព ស្តង់ដារបច្ចេកទេស និងម៉ាកសម្គាល់ច្បាស់លាស់ ដើម្បីតភ្ជាប់សេវាងាយស្រួល និងពុំប្រឈមហានិភ័យដល់សុខភាពនិងអាយុជីវិត
- គួរពិនិត្យចំណុះល្បឿនអ៊ីនធឺណិតរបស់ខ្លួនឱ្យបានទៀងទាត់ ដើម្បីប្រាកដថា ចំណុះល្បឿននោះដូចនឹងកញ្ចប់អ៊ីនធឺណិតដែលបានជាវពីប្រតិបត្តិករ

- ត្រូវបញ្ឈប់ការដំឡើងនិងការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ទទួល-ផ្សាយបន្ត និងគ្រឿងសម្ភារៈបរិក្ខារពង្រីកសេវាទូរសព្ទចល័តដោយខុសច្បាប់
- ក្នុងនាមជាអ្នកប្រើប្រាស់សេវាទូរគមនាគមន៍ ត្រូវសហការរាយការណ៍ពីបាតុភាពនានាពាក់ព័ន្ធនឹងគុណភាពសេវា មានជាអាទិ៍ ភាពមិនគ្រប់គ្រាន់នៃវិសាលភាពគ្របដណ្តប់ ភាពយឺតនៃល្បឿនអ៊ីនធឺណិត ឬភាពរអាក់រអួលនៃការហៅចេញនិងការទទួលទូរសព្ទ នៅតាមទីតាំងនានា ទៅកាន់ភ្នាក់ងារបម្រើសេវាអតិថិជនរបស់បណ្តាប្រតិបត្តិករទូរគមនាគមន៍ តាមរយៈលេខទូរសព្ទដូចមានក្នុងបញ្ជីជូនភ្ជាប់ជាមួយ។ សម្រាប់ព័ត៌មានបន្ថែម អ្នកប្រើប្រាស់សេវាទូរគមនាគមន៍អាចទាក់ទងមកនិយ័តករទូរគមនាគមន៍កម្ពុជា តាមរយៈលេខ ១២៧២ នៅរៀងរាល់ម៉ោងធ្វើការដោយឥតគិតថ្លៃ។

អាស្រ័យហេតុនេះ សូមប្រតិបត្តិករទូរគមនាគមន៍និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃព្រហ ២ រោច ខែ ៨ ៨(ជ) ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២១

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF POST
AND TELECOMMUNICATIONS
№: ....24.MPTC.......

*[Unofficial Translation]*

# Instruction
# On
# Measures to Improve Efficiency and Telecoms Quality of Service

For the purpose of promoting public interest and business integrity and social responsibility, by improving the provision of telecoms services and strengthening the quality of mobile and internet services, the Ministry of Post and Telecommunications (MPTC) would like to inform all telecoms operators and the general public that MPTC has been working to finalize the draft regulations and principles relevant to the improvement of telecoms quality of service (QoS), the implementation of fines and penalties on any telecoms operators who fail to comply with the Law on Telecommunications, and the provision of quality services. MPTC has been measuring telecoms QoS in various locations in order to determine weak spots or other issues affecting QoS, so that appropriate actions can be put in place. In addition, MPTC will require telecoms operators to invest in necessary infrastructure. MPTC will also cooperate with relevant ministries and institutions to effectively facilitate matters in the telecoms sector. The above-mentioned tasks represent the most prioritized activities of the MPTC's reform programs for the telecoms sector.

In order to achieve the reform actions and programs for the telecoms sector, MPTC requires participation from all relevant stakeholders as follows:

**1. Telecoms Operators:**

- Strictly comply with the Law on Telecommunications and relevant regulations;
- Study and update plans to construct base transceiver stations in proportion of usage demand, number of subscribers, and coverage area sizes, and submit the plans to Telecommunication Regulator of Cambodia (TRC);
- Seek approval from TRC prior to constructing base transceiver stations and telecoms networks pursuant to Articles 14 and 17 of the Law on Telecommunications;
- Must seek import, export, supply, and distribution permits and Type Approval certificates for telecoms equipment from TRC, pursuant to Articles 14, 15 and 16 of the Law on Telecommunications;
- Ensure sufficient and stable electricity supply, and prepare electricity reserves at all base transceiver stations;



Address: Building № 13, Preah Monivong Boulevard,
Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia
Website : www.mptc.gov.kh
Tel : (855) 23 724 810
Fax : (855) 23 724 069
Email : info@mptc.gov.kh

- Avoid usage of counterfeit or old equipment, and avoid installations not in accordance with technical standards;
- Organize and revise the network architecture for contingency scenarios in preparing and ensuring high stability for service delivery;
- Strengthen regular maintenance, oversight, and monitoring of the performance of the base transceiver stations (BTS/NodeB/eNodeB) and connectivity network, and increase the capacity of the BTS/NodeB/eNodeB and connectivity network to avoid disruption or network congestion;
- Repair damaged underground fiber optical cable due to road construction or expansion in a timely manner;
- Provide internet service according to the Sharing Factor technical standards without exceeding the available capacity to the consumers;
- Clearly indicate the data speeds and prices in marketing materials and abide by codes and principles of integrity and honesty; and
- Not provide internet services at a speed slower than that listed in the data packages sold to consumers or in the data packages marketed.

**2. Owners of Townships and High-Rise Buildings:**

- Not enter into an exclusive agreement to provide mobile and internet services in their townships and high-rise buildings, which is in violation of fair and lawful competition;
- Reserve a place for base transceiver station(s) in townships or install light poles capable of being equipped with telecoms equipment;
- Cooperate with operators to provide in-building solutions; and
- Treat telecoms services as essential utility services like electricity and water supply.

**3. Citizens:**

- The World Health Organization has confirmed that radio frequency waves do not negatively impact people's health. Transmission of radio frequency waves from base transceiver stations is not an emission of radiation. All countries in the world have constructed and used base transceiver stations to provide telecoms services like Cambodia. If the base transceiver stations do not exist, there will not be any cellular mobile service. If negative health impact exists, countries will not have the base transceiver stations.
- Not prevent the construction of base transceiver stations on the properties of others for negative health impact reasons – such prevention is illegal under the laws and regulations in force;
- Should use quality and standard smartphones with proper trademarks, which allow easy connection and avoid risks to health, life, and service interruption;

- Should accurately check the internet bandwidth to ensure that the bandwidth is the same as the internet package bought from operators; and
- Stop the installation and use of illegal radio-communications repeaters and cellular mobile boosters.
- Telecoms service users must also cooperate and report QoS issues such as poor coverage, slow internet speed, and poor outgoing and incoming calls in various locations, to the telecoms operators' customer service agents at the numbers in the attached list. For further information, users may contact TRC at toll-free 1272 during working hours.

In this regard, telecoms operators and the public shall be informed and cooperate with a sense of responsibility. VA

Phnom Penh, 30 March 2021

និយ័តករទូរគមនាគមន៍កម្ពុជា

## បញ្ជីបច្ចុប្បន្នភាពនៃប្រតិបត្តិករទូរគមនាគមន៍នៅតាមប្រភេទសេវា (គិតត្រឹមខែមីនា ឆ្នាំ២០២១)

| ល.រ | ឈ្មោះក្រុមហ៊ុន | ប្រភេទសេវា | អាសយដ្ឋាន | លេខទូរសព្ទសម្រាប់បណ្ដឹងតវ៉ា |
|---|---|---|---|---|
| 1 | (Cambodia) Fiber Optic Communication Network Co., Ltd. (CFOCN) | -អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា Submarine Cable<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា Optical Cable Networks | #168, St.1946, Phum Tumnub, Sangkat Phnom Penh Thmei, Khan SenSok, Phnom Penh | 071 355 5616<br>011 369 028 |
| 2 | Angkor Cable TV Internet Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា ISP | #12, Phum Ta Phul, Sangkat Svay Dangkum, Krang Siem Reap, Siem Reap Province | 085 365 024<br>086 365 024<br>068 365 024 |
| 3 | Angkor Data Communication Group (ADCG) | អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា ISP | #95, Preah Norodom Blvd, Sangkat Bueong Raing, Khan Daun Penh, Phnom Penh | 023 226 622 |
| 4 | Bee Union (Cambodia) Telecom Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា ISP | # 5659, Street Oknha Mong Rithy (1928), Sangkat Phnom Penh They, Khan Sen Sok, Phnom Penh | 023 911 333 |
| 5 | BigHub Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា ISP | #06, Street 616, Sangkat Boeung Kak 2, Khan Tuol Kok, Phnom Penh | 096 679 9977 |
| 6 | BRANCH OF CHINA TELECOM GLOBAL LIMITED | អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា ISP | Unit 2006, Level 20, Vattanac Capital Tower, No.66, Preah monivong, Sangkat Wat Phnom, Khan Doun Penh, Phnom Penh | 097 991 5858<br>097 973 5858 |
| 7 | Branch of NTT Communications (Thailand) Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា ISP | #Phnom Penh Center, Block"F", Corner Sihanouk (274) & Sothearos (3) Blvd, Tonlebasak, Phnom Penh | 023 221 815<br>077 555 499 |
| 8 | CAMBO Technology Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា ISP | # 1st Floor, Building B, CASA by Meridian, #1, Harvard Street, Koh Pich, Phnom Penh | 081 712 712 |
| 9 | Cambodia Advance Communications (Cadcomms) Co., Ltd. | -អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា VoIP<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា ISP | #825ABC, Monivong Blvd, Sangkat Phsa Demthkov, Khan Chamkarmon, Phnom Penh | 016 460 589 |
| 10 | Cambodian SingMeng Telemedia Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្ដល់សេវា ISP | #29, Street 592, Sangkat Boeung Kok II, Khan Toul Kork, Phnom Penh | 096 666 1888<br>089 966 888<br>078 777 555<br>098 777 555 |

| | | | | |
|---|---|---|---|---|
| 11 | CamGSM Co., Ltd. | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវាទូរសព្ទអចល័តគ្មានខ្សែ<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវាទូរសព្ទចល័ត<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា VoIP | #33, Preah Sihanouk Blvd., Sangkat Boeung Prolit, Khan 7 Makara, Phnom Penh | 012 800 800 |
| 12 | Camintel Co., Ltd. | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវាទូរសព្ទអចល័តមានខ្សែ<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា VoIP<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | # 1, Corner of street. 88 & Sisovath Blvd., Phnom Penh | 023 986 986 |
| 13 | Camtower Link Communication Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា Tower Sharing | #33, Street 200, Block 12 Sangkat Psar Thmey 3, Khan Daun Penh, Phnom Penh, Cambodia. | 023 885 787 |
| 14 | China Unicom (Cambodia) Operations Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | # 14th floor, Exchange Square,No.19-20, Street 106, Sangkat Wat Phnom, Khan Doun Penh, Phnom Penh | 018 980 8808 |
| 15 | Chuan Wei (Cambodia) Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | Regency Square, Complex B, 2nd floor, #8B/294, Moa Tse Tung Blvd, Sangkat Tomnub Teuk, Khan Chamkarmorn, Phnom Penh | 023 722 225 |
| 16 | Citylink Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #105-107, Sihanouk Blvd., Khan 7 Makara, Phnom Penh | 023 220 112 |
| 17 | COGETEL Ltd. | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា VoIP<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #60, Monivong Blvd., Sangkat Wat Phnom, Khan Daun Penh, Phnom Penh | 081 727 272 |
| 18 | Edotco Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា Tower Sharing | Building Keystone, No.146, Unite 3AB, Norodom Blvd., Sangkat Tonle Basac, Khan Chamkarmon, Phnom Penh | 010 208 995<br>010 208 996 |
| 19 | EMPIRE TECH CO., LTD. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | Borei Pipub Thmei, No. 188, Street 10, Phum Bayab, Sangkat Phnom Penh Thmei, Khan Sen Sok, Phnom Penh | 066 938 393 |
| 20 | EZECOM Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #7D, Russian Blvd., Sangkat Toeuk Laork 1, khan Toul Kok, Phnom Penh | 023 888 181<br>085 888 181 |

| | | | | |
|---|---|---|---|---|
| 21 | Fast One (Cambodia) Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #108AB (2Floors), Mao Tse Tung Blvd, Sangkat Toul Tompung2, Khan Chamkar Mon, Phnom Penh | 089 222 551 |
| 22 | Fiber Nanotech (Cambodia) Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #07, Street 26, Tikhakpanhnhor Village, S/k samrong krom, Khan Porsenchey, Phnom Penh | 089 252 522 |
| 23 | GB Net Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #G32-G34-G36, Building Diamond Island Riviera, Room No. 201, Street G, Sangkat Tonle Bassac, Khan Chamkarmon, Phnom Penh | 011 923 876 |
| 24 | King Technologies Co.,Ltd. (Opennet) | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា VoIP<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #49, Street 306, Sangkat Beoung Keng Kong I, Khan Chamkamorn Phnom Penh | 010 670 999<br>070 588 222<br>092 588 222 |
| 25 | Maximum Business Information Technology Co., Ltd. (MaxBIT) | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #229E1, St. 182,Sangkat Toeuk Laak 2, Khan Toul Kok, Phnom Penh. | 023 996 996 |
| 26 | Mega Truenet Communication Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #707 Building Workzone, Floor 5, Room 503, Preah Monivong, Sangkat Boeung Keng Kong, Khan Keng Kong, Phnom Penh | 068 969 611<br>070 969 611 |
| 27 | M-Media Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | Floor 16 of Diamond Twin Tower, Room S1605, Sopheak Mongkol corner Koh Pich St, Sangkat Tonle Bassac,Khan Chamkarmon,PP | 012 869 421<br>098 869 421 |
| 28 | Monorom Advanced Technologies Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #12B, Street No. 3 Borey Phnom Penh Thmey | 012 775 282<br>015 899 859 |
| 29 | Neocom Group Investment Limited | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #19, St. 90, Sangkat Sras Chork , Khan Deun Penh, Phnom Penh. | 093 222 020 |
| 30 | Phnom Penh Cable TV Co., Ltd. (PPCTV) | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #3A,Preah Monireth Blvd, Sangkat Veal Vong,Phnom Penh. | 023 886 333<br>023 886 888 |
| 31 | S.I Group Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | # 93 Preah Sihanouk Blvd, Phnom Penh | 081 901 999 |
| 32 | Sabay Digital Corporation Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #308, Monivong Blvd., Sang Kat Boeung Raing, Khan Daun Penh, Phnom Penh | 023 22 8000 |
| 33 | Smart Axiata Co., Ltd. | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវាទូរសព្ទចល័ត<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា VoIP | #464, Preah Monivong Blvd, Sangkat.Tonle Basak, Phnom Penh | 010 200 888 |

TELECOMMUNICATION REGULATOR OF CAMBODIA
TRC

| | | | | |
|---|---|---|---|---|
| | | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | | |
| 34 | Societe Internationale de Telecommunication Aeronautiques (SITA) | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា Value Added Network Operation | #34E1, Street No. 75, Sangkat Wat Phnom, Khan Daun Penh | 023 235 257<br>012 714 409 |
| 35 | South East Asia Telecom (Cambodia) Co., Ltd. (SEATel) | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ទូរសព្ទអចល័តគ្មានខ្សែ<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ទូរសព្ទចល័ត<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា VoIP<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #149, Street 432, Sangkat Boeng Trabek, Khan Chamkarmorn, Phnom Penh. | 018 980 0800 |
| 36 | Telcotech Limited | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា Submarine Cable | #7D, Russian Blvd., Sankat Tuek Laak1, Khan Tuol Kok, Phnom Penh | 023 888 181<br>085 888 181 |
| 37 | Telecom Cambodia (TC) | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា មាត់ច្រកអន្តរជាតិ<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ទូរសព្ទអចល័តមានខ្សែ<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា VoIP<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា Optical Cable Networks<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | # 95-97, Corner of Sihanouk Blvd., & st. 105, Sangkat Boeung Prolit, Khan 7 Makara, Phnom Penh | 023 722 225 |
| 38 | TELNET Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #12, 6th floor, Street No.348, Sangkat Tuol Svay Prey I, Khan Chamkar Mon, Phnom Penh | 097 513 5135 |
| 39 | TIME DOTCOM (CAMBODIA) CO., LTD. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | LH AROMA Building, Floor 1st, Corner of Street 252 & 107, Sangkat Boeung Prolit, Khan 7 Makara, Phnom Penh | 096 887 8808 |
| 40 | Today Communication Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #64, Street 348, Sangkat Tuol Svay Prey 1, Khan Chamkamorn, Phnom Penh | 023 215 577<br>070 215 577 |

TELECOMMUNICATION REGULATOR OF CAMBODIA

| | | | | |
|---|---|---|---|---|
| 41 | Toll Free Telecom (Cambodia) Co., Ltd. | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា VoIP<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា Toll Free | #39, St.Platinum, Sankat Tomnup Toeuk, Khan Chamkarmorn, Phnom Penh | 023 210 156 |
| 42 | TURBOTECH CO., LTD. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | Street 598, Phum Kha1, Sangkat Chrang Chamreh 2, Khan Russy Keo, Phnom Penh | 068 363 363<br>081 363 363<br>099 363 363 |
| 43 | Viettel (Cambodia) Pte., Ltd. | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា មាត់ច្រកអន្តរជាតិ<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ទូរសព្ទអចល័តមានខ្សែ និងគ្មានខ្សែ<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ទូរសព្ទចល័ត<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា VoIP<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #199, Mao Tse Tung Blvd., Sangkat Toul Svay Prey2, Phnom Penh | 097 909 7097 |
| 44 | Vonet Technology Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #724, floor 11, Room 08 of Apartment Block D, Norodom Blvd, Phum 10, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh | 093 306 960<br>017 973 187<br>097 775 3212 |
| 45 | Wicam Corporation Co., Ltd. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #47, Blvd. 271 corner 480, Sangkat Toul Tompung II, Khan Chamkar Morn, Phnom Penh | 023 224 040<br>010 888 132 |
| 46 | WINGEL COOPERATION CO., LTD. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #50B, Street 602, Sangkat Boeung Kork II, Tuol Kouk, Phnom Penh | 023 977 666<br>023 901 845<br>088 211 8777 |
| 47 | World City Co., Ltd. (Camko City) | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | NO. 256, Street 598, Songkat Toul Songke, Khan Russey keo , Phnom Penh (Camko City) | 098 831 759 |

TELECOMMUNICATION REGULATOR OF CAMBODIA

| | | | | |
|---|---|---|---|---|
| 48 | Xin Wei (Cambodia) Telecom Co., Ltd. | -អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវាទូរសព្ទអចល័តមានគ្មានខ្សែ<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា VoIP<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវាទូរសព្ទចល័ត<br>-អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | #B3 × C3-1, St. 169, Sangkat Veal Vong , Khan 7Makara , Phnom Penh | 038 330 0800 |
| 49 | ZTNET CO., LTD. | អាជ្ញាបណ្ណប្រតិបត្តិការផ្តល់សេវា ISP | No. 124, Room No. 302, Street 388, Sangkat Tuol Svay Prey 1, Khan Chamkarmon, Phnom Penh | 096 267 1515<br>089 555 097 |

ថ្ងៃ ចន្ទ ១ រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១

**ប្រធាន**

**ថោង ចិន្តា**